ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.....................................................

# សុន្ទរកថាបិទ
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ២០២៥
# រវាង ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឡាវ

ថ្ងៃសុក្រ ១៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥

៚៚៚✵៙៙៙

សូមគោរព៖

- លោកជំទាវ Bounkham Vorachit ទេសាភិបាលធនាគារកណ្តាលឡាវ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!

កិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ២០២៥ របស់យើងបានប្រព្រឹត្តទៅក្រោមបរិយាកាសសាមគ្គីភាព ភាតរភាព និងសោមនស្សរីករាយជាមួយនឹងលទ្ធផលប្រកបដោយផ្លែផ្កា។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកជំទាវ ទេសាភិបាល និងសហការីដែលបានចែករំលែកមតិយោបល់លើស្ថានភាពសេដ្ឋកិច្ច ប្រព័ន្ធធនាគារ និងការអនុវត្តគោលនយោបាយរបស់ធនាគារកណ្តាលឡាវ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអបអរចំពោះធនាគារកណ្តាលឡាវ ដែលបានដាក់ចេញនូវវិធានការនិងគោលនយោបាយប្រកបដោយភាពប្រុងប្រយ័ត្ននិងបុរេសកម្ម សំដៅពង្រឹងការគ្រប់គ្រងរូបិយវត្ថុ រក្សាស្ថិរភាពថ្លៃ និងកំណែទម្រង់វិស័យហិរញ្ញវត្ថុ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលសំខាន់ៗដែលកើតចេញពីកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលឡាវ ជាពិសេស ការបញ្ចប់ការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងប្រទេសទាំងពីរ ដែលយើងនឹងសម្ពោធជាផ្លូវការដាក់ឱ្យប្រើប្រាស់នាពេលបន្តិចទៀតនេះ។ ខណៈដែលការតភ្ជាប់នេះគឺជាសមិទ្ធផលជាទី



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

មោទនៈ ការធានាឱ្យប្រព័ន្ធនេះដំណើរការបានដោយពិលាស មានសុវត្ថិភាព និងប្រកបដោយប្រសិទ្ធភាពក៏ជាកិច្ចការមួយ ដែលកាន់តែមានសារៈសំខាន់។ ខ្ញុំមានជំនឿថា ការបន្តកិច្ចសហប្រតិបត្តិការល្អរបស់យើង នឹងបន្តពង្រឹងការតភ្ជាប់សេដ្ឋកិច្ច ជាពិសេស ជំរុញពាណិជ្ជកម្ម និងទេសចរណ៍ ដែលនឹងចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ននៅក្នុងប្រទេសទាំងពីរ។

ជាមួយគ្នានេះ ខ្ញុំសូមគូសបញ្ជាក់ពីសារៈសំខាន់នៃការចែករំលែកនិងការផ្លាស់ប្តូរបទពិសោធរវាងមន្ត្រីបច្ចេកទេសដែលបានអនុវត្តជាច្រើនឆ្នាំកន្លងមក។ ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ ធនាគារជាតិនៃកម្ពុជាបានទទួលស្វាគមន៍មន្ត្រីធនាគារកណ្តាលឡាវមកធ្វើទស្សនកិច្ចសិក្សាចំនួន ២៨រូប ហើយមន្ត្រីធនាគារជាតិនៃកម្ពុជាបានទៅផ្លាស់ប្តូរបទពិសោធនៅធនាគារកណ្តាលឡាវចំនួន ១៦រូប។ ក្នុងន័យនេះ ខ្ញុំសូមឯកភាពទាំងស្រុងជាមួយ លោកជំទាវ ទេសាភិបាល ក្នុងការរក្សានិងបន្តជំរុញវប្បធម៌នៃការចែករំលែកបទពិសោធនិងចំណេះដឹងទៅវិញទៅមក ដែលគាំទ្រដល់ការងារប្រតិបត្តិប្រចាំថ្ងៃ ការរៀបចំនិងការអនុវត្តគោលនយោបាយ ដើម្បីជាប្រយោជន៍ដល់ការពង្រឹងសមត្ថភាពស្ថាប័នក៏ដូចជាប្រទេសទាំងពីរ។

លើសពីនេះ ខ្ញុំក៏សូមសម្តែងនូវការអបអរចំពោះ ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ ខេមបូឌា (CBC) និងក្រុមហ៊ុនចែករំលែកព័ត៌មានឥណទានឡាវ (LCIC) ដែលបានពង្រឹងកិច្ចសហប្រតិបត្តិការដោយបានឈានទៅដល់ការចុះអនុស្សរណៈយោគយល់ ហើយនាថ្ងៃនេះ ការចុះហត្ថលេខានឹងធ្វើឡើងដោយរូបវន្ត ដែលមានទេសាភិបាល និងថ្នាក់ដឹកនាំធនាគារកណ្តាលទាំងពីរជាសាក្សី។ កិច្ចសហប្រតិបត្តិការនេះនឹងផ្តល់នូវអត្ថប្រយោជន៍ដល់ការិយាល័យព័ត៌មានឥណទានទាំងពីរ ក្នុងការលើកកម្ពស់ការផ្តល់ឥណទាននិងការខ្ចីប្រាក់ប្រកបដោយការទទួលខុសត្រូវ តាមរយៈការពង្រឹងតម្លាភាពនិងលើកទឹកចិត្ត ឱ្យអ្នកខ្ចីប្រាក់រក្សាវិន័យឥណទានបានល្អ។ ការណ៍នេះនឹងរួមចំណែកក្នុងការធ្វើការសម្រេចចិត្តបានល្អ កាត់បន្ថយឥណទានមិនដំណើរការ និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។ កិច្ចសហការនេះ ក៏នឹងគាំទ្រដល់សកម្មភាពហិរញ្ញប្បទានឆ្លងដែន សម្របសម្រួលការទទួលបានហិរញ្ញប្បទាន ជាពិសេស សម្រាប់សហគ្រាសធុនមីក្រូ តូចនិងមធ្យម និងបុគ្គលដែលប្រវត្តិឥណទានមានកម្រិត។ ជារួមកិច្ចសហប្រតិបត្តិការនេះនឹងពង្រឹងបរិយាបន្នហិរញ្ញវត្ថុ និងទំនុកចិត្តទីផ្សារ។

ខ្ញុំជឿជាក់ថា មន្ត្រីរបស់យើង ទាំងថ្នាក់ដឹកនាំ ក៏ដូចជា ថ្នាក់បច្ចេកទេសនឹងយកលទ្ធផលនៃកិច្ចប្រជុំរបស់យើងនាពេលនេះ ទៅអនុវត្តឱ្យមានប្រសិទ្ធភាព។ ខ្ញុំក៏សូមស្នើសុំ

ឱ្យភាគីទាំងពីរបន្តការចូលរួមចែករំលែកចំណេះដឹង បទពិសោធ និងឧត្តមានុវត្តន៍ ហើយប្រែក្លាយការពិភាក្សាផ្លាស់ប្តូរទាំងនេះ ទៅជាការអនុវត្តបានយ៉ាងមានប្រសិទ្ធភាព។

**លោកជំទាវ ទេសាភិបាល**

ទស្សនកិច្ចរបស់ លោកជំទាវ មកកាន់រាជធានីភ្នំពេញគ្រានេះមានពេលខ្លី ខ្ញុំសង្ឃឹមថា ដំណើរទស្សនកិច្ចរបស់ លោកជំទាវ នាឱកាសក្រោយនឹងមានរយៈពេលវែង ដែលនឹងអនុញ្ញាតឱ្យយើងបានរៀបចំដំណើរទស្សនកិច្ចទៅកាន់ទីកន្លែងប្រវត្តិសាស្ត្រផ្សេងៗនៅកម្ពុជា ជាពិសេសទៅកាន់តំបន់ប្រាសាទនានានៅខេត្តសៀមរាប។ ខ្ញុំសូមជូនពរ ឱ្យដំណើរត្រឡប់ទៅវិញរបស់ លោកជំទាវ ទេសាភិបាល នារសៀលនេះ ប្រកបដោយសុខសុវត្ថិភាព និងសូមជូនពរគណៈប្រតិភូធនាគារកណ្តាលឡាវ សូមទទួលបានភាពរីករាយនិងអនុស្សាវរីយល្អៗក្នុងការធ្វើដំណើរទស្សនកិច្ចទៅកាន់ខេត្តព្រះសីហនុ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ លោកជំទាវ ទេសាភិបាល និង ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំធនាគារកណ្តាលឡាវ សូមមាន សុភមង្គល សុខភាពល្អបរិបូរណ៍ និង ទទួលបានជ័យជម្នះគ្រប់ភារកិច្ច។ នាឆ្នាំថ្មី ឆ្នាំ២០២៦ ដែលខិតជិតចូលមកដល់ខាងមុខនេះ ខ្ញុំសូមជូនពរ លោកជំទាវ ទេសាភិបាល ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមាន សំណាងល្អ រុងរឿង និងសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត។

**សូមអរគុណ!**